ACLEDA SECURITIES

# ទម្រង់វាយតម្លៃភាពសមស្របរបស់អតិថិជន និងសេចក្តីប្រកាសទទួលស្គាល់ហានិភ័យ (សម្រាប់រូបវន្តបុគ្គល)

# CLIENT'S INVESTMENT SUITABILITY ASSESSMENT AND RISK DECLARATION FORM FOR INDIVIDUAL

| ក្រុមហ៊ុនមូលបត្រ អេស៊ីលីដា ម.ក<br>**ACLEDA Securities Plc.** | ឈ្មោះភ្នាក់ងារចែកចាយលក់មូលនិធិ<br>Fund Selling Representative's Name<br>........................................ | កាលបរិច្ឆេទនៃការវាយតម្លៃ DD / MM / YY<br>Date of application<br>ការវាយតម្លៃលើកទី.............<br>Assessment |
|---|---|---|

## I. ព័ត៌មានអតិថិជន/ Client's Information

លេខគណនីវិនិយោគលើមូលនិធិ **IFA** __ __ __ __ __ __
Investment Fund Account Number

គោត្តនាម និងនាមជាអក្សរខ្មែរ ........................ ជាអក្សរឡាតាំង ........................
Surname and Given Name in Khmer — In Latin

លិខិតសម្គាល់ខ្លួន / Type of ID Card — ☐ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ / Khmer ID Card Number — ☐ លិខិតឆ្លងដែន / Passport — លេខ / Number ........................

## II. ការវាយតម្លៃភាពសមស្របរបស់អតិថិជន/ CLIENT'S INVESTMENT SUITABILITY ASSESSMENT

| | | |
|---|---|---|
| ១- អាយុ<br>1. Ages | ☐ អាយុ ១៨ ទៅ ២៥/ 18 to 25 years old | 4 ពិន្ទុ |
| | ☐ អាយុ ២៦ ទៅ ៤០/ 26 to 40 years old | 3 ពិន្ទុ |
| | ☐ អាយុ ៤១ ទៅ ៦០/ 41 to 60 years old | 2 ពិន្ទុ |
| | ☐ អាយុ ៦១ និងច្រើនជាង/ 61 years old and more than 61 years old | 1 ពិន្ទុ |
| ២- តើអ្នកស្ថិតក្នុងស្ថានភាពមួយណា?<br>2. Which of the following status are you? | ☐ នៅលីវ/ Single | 6 ពិន្ទុ |
| | ☐ រៀបការ ប៉ុន្តែពុំទាន់មានកូន/ Married but childless | 5 ពិន្ទុ |
| | ☐ គ្រួសារវ័យក្មេង និងមានកូន/ Young and fertile families | 4 ពិន្ទុ |
| | ☐ គ្រួសារដែលមានភាពចាស់ទុំ/ Mature family | 3 ពិន្ទុ |
| | ☐ ការរៀបចំសម្រាប់ការចូលនិវត្តន៍/ Preparing for retirement | 2 ពិន្ទុ |
| | ☐ ចូលនិវត្តន៍/ Retired | 1 ពិន្ទុ |
| ៣- តើអ្នកមានបទពិសោធន៍វិនិយោគកម្រិតណា?<br>3. How much investment experience do you have? | ☐ ពុំមានបទពិសោធ/ No experience | 1 ពិន្ទុ |
| | ☐ មានបទពិសោធតិច/ Less experience | 2 ពិន្ទុ |
| | ☐ មានបទពិសោធមធ្យម/ Moderate experience | 3 ពិន្ទុ |
| | ☐ មានបទពិសោធច្រើន/ Deep experience | 4 ពិន្ទុ |
| ៤- តើអ្នកចំណាយប៉ុន្មានភាគរយនៃចំណូលសរុបរបស់អ្នកជាប្រចាំខែ?<br>4. What percentage of your total income do you spend monthly? | ☐ តិចជាង ២៥% នៃចំណូលសរុប/ Less than 25% of total revenue | 4 ពិន្ទុ |
| | ☐ ពី ២៥% ទៅ ៥០% នៃចំណូលសរុប/ 25% to 50% of total revenue | 3 ពិន្ទុ |
| | ☐ ពី ៥១% ទៅ ៧៥% នៃចំណូលសរុប/ 51% to 75% of total revenue | 2 ពិន្ទុ |
| | ☐ ច្រើនជាង ៧៥% នៃចំណូលសរុប/ More than 75% of total revenue | 1 ពិន្ទុ |
| ៥- តើអ្នកពិចារណាធ្វើការវិនិយោគប៉ុន្មានភាគរយនៃទ្រព្យសកម្មដែលអាចវិនិយោគបាន?<br>5. What percentage of assets can you invest in? | ☐ តិចជាង ១០ %/ Less than 10% | 1 ពិន្ទុ |
| | ☐ ពី ១០% ទៅ ២៥ %/ 10% to 25% | 2 ពិន្ទុ |
| | ☐ ពី ២៦% ទៅ ៥០ %/ 26% to 50% | 3 ពិន្ទុ |
| | ☐ ច្រើនជាង ៥០ %/ More than 50% | 4 ពិន្ទុ |
| ៦- សូមជ្រើសរើសចម្លើយល្អបំផុត ដែលពិពណ៌នា អំពីប្រភពចំណូលនាពេលបច្ចុប្បន្ន និងអនាគតរបស់អ្នក។<br>6. Choose the best answer that describes your current and future sources of income. | ☐ ខ្ញុំរំពឹងថា ចំណូលរបស់ខ្ញុំនឹងថយចុះ/ I expect my income will decrease. | 1 ពិន្ទុ |
| | ☐ ខ្ញុំរំពឹងថា ចំណូលរបស់ខ្ញុំនឹងមិនប្រែប្រួល/ I expect my income will not change. | 2 ពិន្ទុ |
| | ☐ ខ្ញុំរំពឹងថា ចំណូលរបស់ខ្ញុំនឹងកើនឡើងស្របទៅនឹងអតិផរណា/ I expect my income will increase in line with inflation. | 3 ពិន្ទុ |
| | ☐ ខ្ញុំរំពឹងថា ចំណូលរបស់ខ្ញុំនឹងកើនឡើងលើសពីអតិផរណា/ I expect my income will increase over than inflation | 4 ពិន្ទុ |
| ៧- សូមជ្រើសរើសគោលបំណងនៃការវិនិយោគរបស់អ្នក<br>7. Choose the purpose of your investment | ☐ ដើម្បីបង្កើនប្រាក់សន្សំសម្រាប់គោលបំណងជាក់លាក់ ឬតម្រូវការក្នុងរយៈពេល ៥ ឆ្នាំ/ To increase savings for specific purposes or demands in 5 years | 1 ពិន្ទុ |
| | ☐ ដើម្បីបង្កើនប្រាក់ចំណូលបន្ថែមសម្រាប់ពេលចូលនិវត្តន៍ ដើម្បីរក្សារបៀបរស់នៅ/ To increase additional income for retirement for maintaining a lifestyle | 2 ពិន្ទុ |
| | ☐ ជាការវិនិយោគទំហំធំ ដើម្បីបង្កើនទ្រព្យសម្បត្តិ/ A large investment to increase wealthiest | 3 ពិន្ទុ |
| | ☐ ជាការវិនិយោគទំហំធំ ដើម្បីទទួលបានចំណូលជាប្រចាំបន្ថែមផ្សេងទៀត/ A large investment to earn other additional regular income | 4 ពិន្ទុ |
| | ☐ ដើម្បីទទួលបានប្រាក់ចំណេញរយៈពេលខ្លី/ For short-term profits | 5 ពិន្ទុ |
| ៨- តើអ្នកអាចទទួលយកហានិភ័យនៃការខាតបង់ប្រាក់វិនិយោគកម្រិតណា?<br>8. How much risk can you take with the loss of your investment? | ☐ ខាតបង់តិចជាង ឬស្មើ ៥%/ Loss less than or equal to 5% | 1 ពិន្ទុ |
| | ☐ ខាតបង់ពី ៦% ទៅ ២៥% / Loss from 6% to 25% | 2 ពិន្ទុ |
| | ☐ ខាតបង់ពី ២៦%ទៅ៤០%/ Loss from 26% to 40% | 3 ពិន្ទុ |
| | ☐ ខាតបង់ពី ៤១% ទៅ ៦០%/ Loss from 41% to 60% | 4 ពិន្ទុ |
| | ☐ ខាតបង់ពី ៦១% ទៅ ៨០%/ Loss from 61% to 80% | 5 ពិន្ទុ |
| | ☐ ខាតបង់ចន្លោះពី ៨១% ទៅ ១០០%/ Loss between 81% to 100% | 6 ពិន្ទុ |

| | | |
|---|---|---|
| ៩. តើអ្នកមានបំណងវិនិយោគនៅក្នុងប្រភេទនៃការវិនិយោគមួយណាខាងក្រោម?<br>9. Which category of the following investment that you intend to invest? | ☐ ប្រភេទទី១- ឱកាសទទួលបានផលចំណេញថេរ ២,៥%<br>Category 1: Opportunity of receive 2.5% Fixed Profit | 1 ពិន្ទុ |
| | ☐ ប្រភេទទី២- ឱកាសទទួលបានផលចំណេញខ្ពស់បំផុត ៧% និងឱកាសខាតបង់ ១%<br>Category 2: Opportunity of receive Maximum profit 7% and 1% loss | 2 ពិន្ទុ |
| | ☐ ប្រភេទទី៣- ឱកាសទទួលបានផលចំណេញខ្ពស់បំផុត ១៥% និងឱកាសខាតបង់ ៥%<br>Category 3: Opportunity of receive 15% maximum profit and 5% loss | 3 ពិន្ទុ |
| | ☐ ប្រភេទទី៤- ឱកាសទទួលបានផលចំណេញខ្ពស់បំផុត ២៥% និងឱកាសខាតបង់ ១៥%<br>Category 4: Opportunity of receive 25% maximum profit and 15% loss | 4 ពិន្ទុ |
| ១០.ប្រសិនបើឆ្នាំមុនអ្នកបានវិនិយោគ ១០.០០០.០០០ រៀល ហើយឆ្នាំនេះសមតុល្យនៃការវិនិយោគរបស់អ្នកនៅត្រឹម ៩.០០០.០០០ រៀល។ តើអ្នកនឹងធ្វើអ្វី?<br>10. If last year you invested 10,000,000 Riel and this year your investment balance is 9,000,000 Riel. What will you do? | ☐ ភ័យស្លន់ស្លោ និងចង់លក់ត្រឡប់ទៅវិញនូវឯកតាមូលនិធិដែលមានទាំងអស់<br>Panic and want to redemption all orderable fund units | 1 ពិន្ទុ |
| | ☐ ព្រួយបារម្ភ និងកែសម្រួលផលបត្រនៃការវិនិយោគ ដើម្បីកាត់បន្ថយហានិភ័យ<br>Concerns and adjusts investment portfolio to reduce risk | 2 ពិន្ទុ |
| | ☐ រក្សាការបណ្ដាក់ទុន ហើយរង់ចាំផលចំណេញមកវិញ<br>Keep investing and wait for returns | 3 ពិន្ទុ |
| | ☐ នៅតែមានទំនុកចិត្ត និងយល់ថាការវិនិយោគត្រូវតែមានរយៈពេលវែង និងនៅបន្តវិនិយោគបន្ថែមទៀត ដើម្បីកាត់បន្ថយថ្លៃដើមជាមធ្យម<br>Remain confident, understand that the investment must be long-term, and continue to invest more to reduce the average cost. | 4 ពិន្ទុ |
| ១១.សូមជ្រើសរើសចម្លើយមួយដែលឆ្លុះបញ្ចាំងពីឥរិយាបទរបស់អ្នកក្នុងនាមជាវិនិយោគិនៈ<br>11. Choose an answer that reflects your attitude as an investor: | ☐ ខ្ញុំចង់រក្សាឱ្យបាននូវដើមទុនវិនិយោគ ទោះបីជាអត្រាផលចំណេញពីការវិនិយោគទាបជាង អត្រាអតិផរណា<br>I want to maintain investment capital even if the return on investment is lower than the inflation rate. | 1 ពិន្ទុ |
| | ☐ ខ្ញុំហ៊ានប្រឈមនឹងហានិភ័យនៃការខាតបង់ខ្លះដរាបណាអត្រាផលចំណេញពីការវិនិយោគអាចស្របទៅនឹងអត្រាអតិផរណា<br>I dare to take risk on some losses as long as the return on investment can match the inflation rate. | 2 ពិន្ទុ |
| | ☐ ខ្ញុំអាចទទួលយកហានិភ័យកម្រិតមធ្យម ដើម្បីទទួលបាននូវកំណើនដើមទុនលើសអតិផរណាបន្តិច<br>I can take moderate risks to get capital growth slightly over than inflation | 3 ពិន្ទុ |
| | ☐ ខ្ញុំអាចទទួលយកហានិភ័យកម្រិតខ្ពស់ ដើម្បីទទួលបានផលចំណេញដែលមានសក្ដានុពលខ្ពស់<br>I can take high risk to get high potential profit | 4 ពិន្ទុ |
| ១២.ការវិនិយោគដែលមានបម្រែបម្រួលខ្លាំងអាចផ្ដល់ផលចំណេញច្រើនក្នុងរយៈវែង ខណៈដែលការវិនិយោគដែលមានលក្ខណៈអភិរក្ស អាចទទួលបានផលចំណេញទាបជាងអត្រាអតិផរណា។ តើអ្នកអាចទទួលយកបម្រែបម្រួលនៅក្នុងទីផ្សារកម្រិតណា?<br>12. Highly volatile investments can pay off in the long run, while conservative investments can yield lower returns compared to inflation. What extend level can you accept in the market? | ☐ តិចតួចបំផុត/ Minimal | 1 ពិន្ទុ |
| | ☐ តិចតួច/ Little | 2 ពិន្ទុ |
| | ☐ មធ្យម/ Medium | 3 ពិន្ទុ |
| | ☐ ខ្លាំង/ High | 4 ពិន្ទុ |
| ១៣-តើអ្នកធ្លាប់បានវិនិយោគរយៈពេលប៉ុន្មានឆ្នាំហើយ ដោយមិនរាប់បញ្ចូលការទិញផ្ទះរបស់អ្នក ឬការដាក់ប្រាក់បញ្ញើនៅធនាគារ?<br>13. How many years have you invested, excluding buying your home or putting a deposit in the bank? | ☐ នេះគឺជាការវិនិយោគលើកដំបូងរបស់ខ្ញុំ/ This is my first investment | 1 ពិន្ទុ |
| | ☐ តិចជាង ៣ ឆ្នាំ/ Less than 3 years | 2 ពិន្ទុ |
| | ☐ ពី ៣ ឆ្នាំ ទៅ តិចជាង ៦ ឆ្នាំ/ From 3 years to less than 6 years | 3 ពិន្ទុ |
| | ☐ ពី ៦ ទៅ តិចជាង ៩ ឆ្នាំ/ From 6 years to less than 9 years | 4 ពិន្ទុ |
| | ☐ ពី ៩ ឆ្នាំឡើង/ From 9 years up | 5 ពិន្ទុ |
| ១៤-សូមជ្រើសរើសរយៈពេលវិនិយោគរំពឹងទុករបស់អ្នក<br>14. Please choose your expected investment period | ☐ តិចជាង ១ ឆ្នាំ/ Less than 1 year | 1 ពិន្ទុ |
| | ☐ ពី ១ ឆ្នាំ ទៅតិចជាង ៣ ឆ្នាំ/ 1 year to less than 3 years | 2 ពិន្ទុ |
| | ☐ ពី ៣ ឆ្នាំ ទៅតិចជាង ៥ ឆ្នាំ/ From 3 years to less than 5 years | 3 ពិន្ទុ |
| | ☐ ពី ៥ ឆ្នាំឡើង/ 5 years up | 4 ពិន្ទុ |
| | ពិន្ទុសរុប<br>Total score | .......... |

**សម្រាប់ក្រុមហ៊ុន មូលបត្រ អេស៊ីលីដា ម.ក តែប៉ុណ្ណោះ**
**For ACLEDA Securities Plc only**

ឥរិយាបថវិនិយោគរបស់អតិថិជនដែលត្រូវបានកំណត់ដោយផ្អែកលើកម្រងសំណួរខាងលើស្ថិតក្នុងកម្រិតដូចខាងក្រោម
Customer investment behavior determined based on the above questionnaire is at the following levels:

☐ ហានិភ័យកម្រិតទាប (ពិន្ទុពី ១៤ ទៅ ៣១)
Low risk (14 to 31 points)

☐ ហានិភ័យកម្រិតមធ្យម (ពិន្ទុពី ៣២ ទៅ ៤៩)
Medium risk (score 32 to 49)

☐ ហានិភ័យកម្រិតខ្ពស់ (ពិន្ទុពី ៥០ ទៅ ៦៧)
High risk (score from 50 to 67)

**ហត្ថលេខាភ្នាក់ងារចែកចាយលក់មូលនិធិ**
Signature of Fund Selling Representative

ឈ្មោះភ្នាក់ងារចែកចាយលក់មូលនិធិ ..........................................
Fund Selling Representative's name

ធ្វើនៅ.................................... , ថ្ងៃទី.................. ខែ................. ឆ្នាំ..................
Place Date Month Year

## ឥរិយាបថចំពោះការវិនិយោគ និងប្រភេទនៃមូលនិធិសមស្របសម្រាប់ការវិនិយោគដោយផ្អែកទៅលើកម្រិតហានិភ័យ
## Investment attitudes and types of funds suitable for investment based on risk level

| | ហានិភ័យកម្រិតទាប<br>**Low Risk** | ហានិភ័យកម្រិតមធ្យម<br>**Medium Risk** | ហានិភ័យកម្រិតខ្ពស់<br>**High Risk** |
|---|---|---|---|
| **ឥរិយាបថចំពោះការវិនិយោគ**<br>**Investment Behavior** | អ្នកគឺជាវិនិយោគិនដែលដែលមានទំនោរលើការវិនិយោគដែលមានហានិភ័យទាប និងរក្សាដើមទុនវិនិយោគពីការខាតបង់។ អ្នកសុខចិត្តទទួលបានផលចំណេញតិច ដើម្បីកុំឱ្យមានការព្រួយបារម្ភពិការខាតបង់ច្រើននៅក្នុងការវិនិយោគ។<br>You are an investor who tends to invest in low risk and keep your investment capital from a loss. You are willing to make a small profit so that you do not have to worry about losing your investment. | អ្នកគឺជាវិនិយោគិនដែលដែលមានទំនោរលើការវិនិយោគដែលមានមានហានិភ័យមធ្យម។ អ្នកហ៊ានទទួលយកហានិភ័យកម្រិតមធ្យមចំពោះការវិនិយោគដែលមានសក្តានុពលក្នុងការកើនឡើងនៃតម្លៃក្នុងរយៈពេលមធ្យមទៅរយៈពេលវែង។<br>You are an investor who tends to invest in medium risk. You dare to take a minimal risk on an investment that has the potential to increase value in the medium to long term. | អ្នកគឺជាវិនិយោគិនដែលមានទំនោរទៅលើការវិនិយោគដែលមានហានិភ័យខ្ពស់។ អ្នកហ៊ានទទួលយកហានិភ័យខ្ពស់ចំពោះការយកហានិភ័យកម្រិតខ្ពស់ ចំពោះ ការវិនិយោគដែលមានសក្តានុពលខ្ពស់ក្នុងការបង្កើនតម្លៃដើមទុន វិនិយោគក្នុងរយៈពេលវែង។<br>You are an investor who tends to invest in high risk. You dare and accept to take a high risk on an investment that has a high potential to increase the value of investment capital in the long term. |
| **ប្រភេទនៃមូលនិធិសមស្របសម្រាប់ការវិនិយោគ**<br>**Types of Funds Suitable to Invest** | - មូលនិធិដែលមានហានិភ័យទាប<br>Low risk fund | - មូលនិធិដែលមានហានិភ័យទាប<br>Low risk fund<br>- មូលនិធិដែលមានហានិភ័យមធ្យម<br>Medium Risk Fund | - មូលនិធិដែលមានហានិភ័យទាប<br>Low risk fund<br>- មូលនិធិដែលមានហានិភ័យមធ្យម<br>Medium Risk Fund<br>- មូលនិធិដែលមានហានិភ័យខ្ពស់<br>High Risk Fund |

☐ ខ្ញុំយល់ស្របលើការវាយតម្លៃចំណាត់ថ្នាក់ហានិភ័យខាងលើនេះហើយទទួលស្គាល់ថាបានទទួលនូវបញ្ជីមូលនិធិដែលផ្តល់ដោយ ក្រុមហ៊ុនមូលបត្រ អេស៊ីលីដា ម.ក។

☐ I agree to the above risk rating assessment and acknowledge received the list of funds that has been provided by ACLEDA Securities Plc.

☐ ខ្ញុំមិនយល់ស្របនឹងការវាយតម្លៃចំណាត់ថ្នាក់ខាងលើនេះទេ។ខ្ញុំមានការយល់ដឹងយ៉ាងពេញលេញអំពីហានិភ័យពាក់ព័ន្ធនឹងការវិនិយោគលើមូលនិធិ។ខ្ញុំ ទទួលស្គាល់ថាបានទទួលនូវបញ្ជីមូលនិធិដែលផ្តល់ដោយ ក្រុមហ៊ុនមូលបត្រ អេស៊ីលីដា ម.ក។

☐ I do not agree with the above rating evaluation. I am fully aware of the risks involved in investing in a fund. I acknowledge received the list of funds that has been provided by ACLEDA Securities Plc.

## កត្តាហានិភ័យ
## Risk factors

ការវិនិយោគលើមូលនិធិនៃគម្រោងវិនិយោគរួមអាចប្រឈមនឹងហានិភ័យ ដូចនេះ អតិថិជនត្រូវពិចារណាលើប្រភេទមូលនិធិនៃគម្រោងវិនិយោគរួមនីមួយៗ បទពិសោធន៍ និងប្រភពហិរញ្ញវត្ថុរបស់អតិថិជនផ្ទាល់ ដើម្បីប្រាកដថាអតិថិជនអាចធ្វើការវិនិយោគលើមូលនិធិនៃគម្រោងវិនិយោគរួមបាន។ ទោះបីជាអតិថិជនមាន បទពិសោធន៍ក្នុងការវិនិយោគលើមូលនិធិនៃគម្រោងវិនិយោគរួមក៏ដោយ ក៏អតិថិជននៅតែត្រូវយល់អំពីហានិភ័យ ចម្បងៗពាក់ព័ន្ធនឹងការវិនិយោគរបស់ខ្លួនដូចខាងក្រោម៖

Investing in collective investment scheme fund can be risky, so clients need to consider the type of fund of each collective investment scheme, the own experience and financial resources to ensure that clients can invest in collective investment scheme fund. Although clients have experience in investing in collective investment scheme fund, clients still need to understand the following main risks associated with their investment:

### ក- ហានិភ័យទីផ្សារ

ការប្រែប្រួលនៃសេដ្ឋកិច្ច លក្ខខណ្ឌទីផ្សារហិរញ្ញវត្ថុ ឬគោលនយោបាយរបស់រាជរដ្ឋាភិបាល អាចប៉ះពាល់ ដល់ថ្លៃមូលបត្រ ឬឧបករណ៍មូលដ្ឋាន (underlying instrument) ដែលវិនិយោគដោយមូលនិធិនៃគម្រោង វិនិយោគរួម និងបណ្តាលឱ្យមានការប្រែប្រួលថ្លៃនៃឯកតាមូលនិធិ។

**a. Market Risk**

Changes in the economy, financial market conditions or government policies can affect the price of securities or underlying instruments invested by the fund of a collective investment scheme and cause a change in the price of the unit fund.

### ខ- ហានិភ័យឥណទាន

សមិទ្ធកម្មរបស់មូលនិធិនៃគម្រោងវិនិយោគរួមអាចរងឥទ្ធិពលពីសមិទ្ធកម្ម ឬសមត្ថភាពនៃការធ្វើធុរកិច្ច របស់ធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្របំណុល ឬក្រុមហ៊ុនធុរកិច្ចផ្សេងទៀត ដែលវិនិយោគដោយមូលនិធិនៃគម្រោងវិនិយោគរួម។ ហានិភ័យឥណទានឆ្លុះបញ្ចាំងពីលទ្ធភាពរបស់ធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្របំណុល ឬក្រុមហ៊ុនធុរកិច្ចផ្សេងទៀត ក្នុងការបំពេញ កាតព្វកិច្ចហិរញ្ញវត្ថុរបស់ខ្លួន។

**b. Credit Risk**

The performance of the fund of collective investment scheme may be influenced by the achievements or business capabilities of banks, microfinance institutions, issuers, bonds or other business entities invested by the fund of collective investment scheme. Credit risk reflects the ability of banks, microfinance institutions, issuers, bonds or other businesses to meet their financial obligations.

### គ- ហានិភ័យអត្រាការប្រាក់

ហានិភ័យនៃការប្រែប្រួលនៃអត្រាការប្រាក់អាចប៉ះពាល់ដល់ថ្លៃមូលបត្របំណុល ឬឧបករណ៍មូលដ្ឋាន និងដល់សមិទ្ធកម្មរបស់មូលនិធិនៃគម្រោងវិនិយោគរួម។ នៅពេលដែលអត្រាការប្រាក់កើនឡើង ថ្លៃមូលបត្រ បំណុលនឹងធ្លាក់ចុះ ប៉ុន្តែនៅពេលដែលអត្រាការប្រាក់ធ្លាក់ចុះ ថ្លៃមូលបត្របំណុលនឹងកើនឡើង។

**c. Interest Rate risk**

The risk of interest rate fluctuations may affect the cost of bond or underlying instruments and the fund performance. As interest rates rise, bond prices fall, but as interest rates fall, bond prices rise.

### ឃ- ហានិភ័យសន្ទនីយភាព

មូលបត្រ ឬឧបករណ៍មូលដ្ឋាន ដែលវិនិយោគដោយមូលនិធិនៃគម្រោងវិនិយោគរួមអាចមានកម្រិត សន្ទនីយភាពទាប ឬមិនមានសន្ទនីយភាព ដោយសារការថយចុះនៃតម្រូវការ ឬកត្តាពាក់ព័ន្ធផ្សេងទៀតដែលអាចជះឥទ្ធិពលអវិជ្ជមានលើតម្លៃនៃទ្រព្យសកម្ម ការលក់ចេញនៃទ្រព្យសកម្ម និងសមិទ្ធកម្មរបស់មូលនិធិនៃគម្រោងវិនិយោគរួម។

**d. Liquidity Risks**

Underlying securities or equity investments may have low or no liquidity due to declining demand or other relevant factors that may adversely affect asset value, asset sales and performance of the collective investment scheme fund.

**ង- ហានិភ័យអត្រាប្តូរប្រាក់**

ក្នុងករណីដែលការវិនិយោគរបស់មូលនិធិនៃគម្រោងវិនិយោគរួមពាក់ព័ន្ធនឹងប្រតិបត្តិការជារូបិយប័ណ្ណបរទេស តម្លៃនៃរូបិយប័ណ្ណបរទេសនោះអាចមានការប្រែប្រួល។ អត្រាប្តូរប្រាក់អាចធ្វើឱ្យតម្លៃនៃការវិនិយោគរបស់ មូលនិធិនៃគម្រោងវិនិយោគរួម ឡើង ឬចុះ ហើយជះឥទ្ធិពលលើសមិទ្ធកម្មរបស់មូលនិធិនៃគម្រោងវិនិយោគរួម។

**e. Exchange Rate Risk**

In case the investment of the collective investment scheme fund involves a transaction in foreign currency, the value of that foreign currency may fluctuate. The exchange rate can increase or decrease the value of the investment of the collective investment scheme fund and affect the performance of the collective investment scheme fund.

**ច- ហានិភ័យបទប្បញ្ញត្តិ**

ហានិភ័យទាក់ទងនឹងការប្រែប្រួល ឬការអនុវត្តច្បាប់ បទប្បញ្ញត្តិ និងអភិបាលកិច្ចនៃទីផ្សារមូលដ្ឋានដែល ត្រូវបានវិនិយោគដោយមូលនិធិនៃគម្រោងវិនិយោគរួម ឬនៃការគ្រប់គ្រងមូលនិធិនៃគម្រោងវិនិយោគរួម អាចធ្វើ ឱ្យមានភាពមិនច្បាស់លាស់ និងការប្រែប្រួលខ្លាំងនៃថ្លៃមូលបត្រ ឬឧបករណ៍មូលដ្ឋានដែលវិនិយោគដោយ មូលនិធិនៃគម្រោងវិនិយោគរួម និងសមិទ្ធកម្មរបស់មូលនិធិនៃគម្រោងវិនិយោគរួម។

**f. Regulatory Risk**

Risks related to changes or enforcement of laws, regulations and governance of the local market invested by the collective investment scheme fund or of the fund management of the collective investment scheme fund may cause uncertainty and significant fluctuations in the price of securities or basic tools invested by the collective investment scheme fund and the achievements of the collective investment scheme fund.

**ឆ- ហានិភ័យនៃការអនុវត្តស្តង់ដាគណនេយ្យ**

គោលនយោបាយគណនេយ្យនៅក្នុងប្រទេសនីមួយៗអាចមានភាពខុសគ្នា និងអាចមិនស្របតាមការ អនុវត្តជាអន្តរជាតិ ហើយអាចបង្កឱ្យមានហានិភ័យក្នុងការវាយតម្លៃទ្រព្យសកម្ម និងតម្លាភាពនៃគណនេយ្យ និងអាចប៉ះពាល់ដល់សមិទ្ធកម្មរបស់មូលនិធិនៃគម្រោងវិនិយោគរួម។

**g. Accounting Practice Risk**

Accounting policies in each country may vary and may not be in line with international practice and may pose a risk to asset valuation and transparency of accounting and may affect the fund performance of collective investment scheme.

**ជ-ហានិភ័យនៃការអនុវត្តកិច្ចសន្យា និងសមភាគី**

ប្រទេសខ្លះមិនមានប្រព័ន្ធដែលមានប្រសិទ្ធភាពសម្រាប់ការផ្ទេរ និងការកំណត់ថ្លៃទ្រព្យសកម្មនោះទេដែល អាចនាំឱ្យមានការលំបាកក្នុងការអនុវត្តកិច្ចសន្យាជាមួយសមភាគី។ ការណ៍នេះអាចធ្វើឱ្យការអនុវត្តនៃកិច្ចសន្យា ប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីនៃកិច្ចសន្យា និងសមិទ្ធកម្មរបស់មូលនិធិនៃគម្រោងវិនិយោគរួម។

**h. Execution and Counterparty Risk**

Some countries do not have effective systems for transferring and setting asset value, which can lead to difficulties in executing contracts with counterparts. This may affect the performance of the contract, the interests of the parties to the contract and the fund performance of the collective investment scheme.

**ឈ- ហានិភ័យធុរកិច្ច**

ហានិភ័យដែលកើតចេញពីស្ថានភាពធុរកិច្ច និងវិស័យពាក់ព័ន្ធ អាចជះឥទ្ធិពលលើប្រតិបត្តិការរបស់ក្រុមហ៊ុន ឬតម្លៃនៃឧបករណ៍មូលដ្ឋានដែលមានការពាក់ព័ន្ធជាមួយការវិនិយោគរបស់មូលនិធិនៃគម្រោងវិនិយោគរួម។ ការណ៍នេះអាចជះឥទ្ធិពលអវិជ្ជមានលើសមិទ្ធកម្មរបស់មូលនិធិនៃគម្រោងវិនិយោគរួម។

**i. Business Risk**

Risks arising from the business status and related sectors may affect the Company's operations or the value of the underlying equipment associated with the investment of the collective investment scheme fund. This can have a negative impact on the performance of the collective investment scheme fund.

**ញ- ហានិភ័យប្រទេស និងនយោបាយ**

ហានិភ័យដែលកើតចេញពីអស្ថិរភាពសេដ្ឋកិច្ច សង្គម និងនយោបាយនៃប្រទេសដែលពាក់ព័ន្ធនឹងការវិនិយោគរបស់មូលនិធិនៃគម្រោងវិនិយោគរួម អាចជះឥទ្ធិពលលើថ្លៃនៃមូលបត្រ ឬឧបករណ៍មូលដ្ឋាន សន្ទនីយភាពទីផ្សារ លក្ខខណ្ឌទីផ្សារ អតិផរណា ឬអត្រាប្តូរប្រាក់នៅក្នុងប្រទេសនោះ ហើយអាចបណ្តាលឱ្យមូលនិធិនៃគម្រោងវិនិយោគរួមមិនអាចទទួលបានផលចំណេញតាមការរំពឹងទុក។

**j. Country and Political Risk**

Risks arising from the socio-economic and political instability of a country involving in the investment of collective investment scheme funds may affect the price of securities or instruments, market liquidity, market conditions, inflation or exchange rates in that country and may cause collective investment scheme funds are not as profitable as expected.

## សេចក្តីប្រកាសទទួលស្គាល់
## Declaration

- ខ្ញុំយល់ព្រមនិងទទួលស្គាល់ថាឥរិយាបថចំពោះការវិនិយោគដែលទទួលបានពីការវាយតម្លៃភាពសមស្របរបស់ខ្ញុំនៅក្នុងទម្រង់នេះ នឹងពុំមានការប្រែប្រួលនោះទេ លុះត្រាតែមានការវាយតម្លៃឡើងវិញ តាមការស្នើសុំរបស់ខ្ញុំនាពេលអនាគត ជាមួយនឹងភ្នាក់ងារចែកចាយលក់មូលនិធិ។
- ខ្ញុំនឹងចូលរួមសហការទទួលយកការវាយតម្លៃភាពសមស្របរបស់ខ្ញុំសម្រាប់ការវិនិយោគលើមូលនិធិម្តងទៀត ក្នុងករណីមាន ការតម្រូវពីក្រុមហ៊ុនមូលបត្រ អេស៊ីលីដា ម.ក។
- ខ្ញុំទទួលស្គាល់ថា រាល់ព័ត៌មានដែលខ្ញុំបានផ្តល់ជូនខាងលើនេះ គឺជាព័ត៌មានដែល ពិតប្រាកដ និងត្រឹមត្រូវទាំងស្រុង។
- ខ្ញុំសូមប្រកាសទទួលស្គាល់ថា បានទទួលការពន្យល់ពីភ្នាក់ងារចែកចាយលក់មូលនិធិ និងយល់ដឹងអំពីហានិភ័យចម្បងៗពាក់ព័ន្ធនឹងការវិនិយោគលើមូលនិធិនៃគម្រោងវិនិយោគរួម។

- I agree and acknowledge that the attitude towards the investment obtained from my suitability assessment in this form will not change unless there is a re-assessment at my request in the future with the agency. Distribute funds
- I will co-operate to accept my assessment of suitability for re-investment of funds in case of need from distributors, repurchases and repayments.
- I acknowledge that all the information I have provided above is true and correct.
- I would like to acknowledge that I have received an explanation from the fund selling representative and understand the main risks associated with investing in the funds of collective investment.

## អតិថិជន
## Client

| | |
|---|---|
| **ហត្ថលេខា ឬស្នាមម្រាមដៃ**<br>**Signature Or Fingerprint** | |
| ឈ្មោះអតិថិជនៈ<br>Client's name | ................................................................................ |
| ធ្វើនៅ, កាលបរិច្ឆេទៈ<br>Place, Date | ធ្វើនៅ.................................................. , ថ្ងៃទី........................ ខែ...................... ឆ្នាំ..................<br>Place Date Month Year |